# ធនាគារ ព្រីនស៍ ម.ក

## បញ្ញត្តិ និងលក្ខខណ្ឌសម្រាប់កម្មវិធីលើកទឹកចិត្តប្រើប្រាស់ប័ណ្ណ MASTERCARD ជាមួយ BookMeBus

ធនាគារ ព្រីនស៍ ម.ក ("**ធនាគារ ព្រីនស៍**") កំពុងដាក់ដំណើរការកម្មវិធីលើកទឹកចិត្តប្រើប្រាស់ប័ណ្ណ MasterCard ជាមួយBookMeBus ដោយអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌ ដែលបានចែងនៅទីនេះ ("**កម្មវិធីលើកទឹកចិត្ត**")។ តាមរយៈការចូលរួមកម្មវិធីលើកទឹកចិត្តនេះ អតិថិជន យល់ព្រមអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌដូចខាងក្រោម ព្រមទាំងបញ្ញត្តិ និងលក្ខខណ្ឌទូទៅ បញ្ញត្តិ និងលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណឥណទាន បញ្ញត្តិ និងលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណ និងបញ្ញត្តិ និងលក្ខខណ្ឌដែលពាក់ព័ន្ធដទៃទៀត៖

១. រាល់ អតិថិជនជារូបវន្តបុគ្គលដែលកំពុងប្រើប្រាស់ប័ណ្ណឥណពន្ធ ឬប័ណ្ណឥណទាន MasterCard (ប្រភេទ Standard ឬ Platinum) ចេញជូនដោយ ធនាគារ ព្រីនស៍ ("**អ្នកចូលរួម**") អាចចូលរួមកម្មវិធីលើកទឹកចិត្តនេះ។

២. អតិថិជនដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម នឹងទទួលបាននូវរង្វាន់លើកទឹកចិត្ត ("**រង្វាន់លើកទឹកចិត្ត**") ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌខាងក្រោម។

| ប្រភេទប្រតិបត្តិការ | ពាណិជ្ជករ | រង្វាន់លើកទឹកចិត្ត | រយៈពេលកម្មវិធីលើកទឹកចិត្ត |
|---|---|---|---|
| ប្រតិបត្តិការទិញអនឡាញ ដោយប្រើប្រាស់ប័ណ្ណ MasterCard ធនាគារ ព្រីនស៍ (ទាំងប័ណ្ណឥណពន្ធ ឬប័ណ្ណឥណទាន) | កម្មវិធីទូរសព្ទ BookMeBus App ឬគេហទំព័រ (https://bookmebus.com/) | ចុះតម្លៃ៥០% ភ្លាមៗ នៃវិក្កយបត្រ (កម្រិតត្រឹម ៥$ ក្នុងមួយវិក្កយបត្រ) | ០៨ វិច្ឆិកា ដល់ ៣០ វិច្ឆិកា ២០២៤ |

៣. រង្វាន់លើកទឹកចិត្ត ផ្តល់ជូនអ្នកចូលរួមដោយអនុលោមតាម បញ្ញត្តិ និងលក្ខខណ្ឌនេះ នៅក្នុងរយៈពេលកម្មវិធីលើកទឹកចិត្ត ឬរហូតដល់ពេលដែលគម្រោងថវិកាដែលត្រូវបានអនុម័តសម្រាប់កម្មវិធីលើកទឹកចិត្តនេះ ត្រូវបានចំណាយអស់។

៤. ក្នុងករណីមានការឆបោក ឬក្លែងបន្លំដែលប្រព្រឹត្តដោយ ឬមានពាក់ព័ន្ធនឹងអ្នកចូលរួមទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ អ្នកចូលរួមរូបនោះនឹងបាត់បង់សិទ្ធិចូលរួមកម្មវិធីលើកទឹកចិត្តនេះ ដោយរួមទាំងអត្ថប្រយោជន៍ផ្សេងៗដែលខ្លួនទទួលបាន។ អ្នកចូលរួមត្រូវប្រគល់ជូនធនាគារ ព្រីនស៍ វិញ នូវរាល់អត្ថប្រយោជន៍ដែលខ្លួនបានទទួលពី ធនាគារ ព្រីនស៍ តាមរយៈកម្មវិធីលើកទឹកចិត្តនេះ (ប្រសិនបើមាន) និងត្រូវសងសំណងការខូចខាតផ្សេងៗទៅតាមបញ្ញត្តិច្បាប់ជាធរមាន។

៥. ការរក្សាសិទ្ធិ ការរួចផុត និងការកម្រិតនៃការទទួលខុសត្រូវ

ក. អ្នកចូលរួម យល់ព្រមថា ធនាគារ ព្រីនស៍ រួមបញ្ចូលទាំង ម្ចាស់ភាគហ៊ុន អភិបាល ឬបុគ្គលិក របស់ ធនាគារ ព្រីនស៍ មិនត្រូវទទួលខុសត្រូវលើ រាល់ការខូចខាតណាមួយ ទោះដោយផ្ទាល់ ឬ ដោយប្រយោល ជាពិសេស ឬដោយចៃដន្យ ដែលកើតឡើង ទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ ឡើយ។

ខ. អ្នកចូលរួម យល់ព្រមដោយមិនអាចដកហូតវិញបានថា អ្នកចូលរួមយល់ព្រមសងសំណង និង ធានាថា ធនាគារ ព្រីនស៍ នឹងទទួលបានសំណងគ្រប់ពេលណាមួយ លើរាល់ការបាត់បង់ ការខូច ខាត កម្រៃសេវា កម្រៃសេវាផ្លូវច្បាប់ និងការចំណាយផ្សេងៗ និងរាល់ផលវិបាកដែលកើតឡើងលើ ធនាគារ ព្រីនស៍ ឬបានទទួលរងដោយ ធនាគារ ព្រីនស៍ ចំពោះការទាមទារ ឬបណ្តឹងណាមួយ ដែលធ្វើឡើងដោយអ្នកចូលរួម ឬភាគីទីបី ដែលកើតឡើង ឬទាក់ទងនឹងបញ្ញត្តិដែលមានចែងក្នុង បញ្ញត្តិនិងលក្ខខណ្ឌនេះ។

គ. ធនាគារ ព្រីនស៍ មិនទទួលខុសត្រូវ ទោះក្នុងទម្រង់ណាមួយ ចំពោះការខូចខាត ឬការខាតបង់ ដែលកើតចេញពីប្រតិបត្តិការរវាងអ្នកចូលរួម និងBookMeBusឡើយ។

៦. ធនាគារ ព្រីនស៍ រក្សាសិទ្ធិគ្រប់យ៉ាង ក្នុងការធ្វើវិសោធនកម្មលើបញ្ញត្តិនិងលក្ខខណ្ឌនេះ ពន្យាពេល បន្ថែមរយៈពេល ឬលុបចោលកម្មវិធីលើកចិត្តនេះ និង/ឬរង្វាន់លើកទឹកចិត្ត នៅពេលណាមួយក្នុងរយៈ ពេលកម្មវិធីលើកទឹកចិត្ត ដោយមិនមានការទទួលខុសត្រូវ តាមឆន្ទានុសិទ្ធិដាច់ខាតរបស់ ធនាគារ ព្រីនស៍ ដោយគ្រាន់តែផ្តល់ការជូនដំណឹងពីការផ្លាស់ប្តូរ នៅលើគេហទំព័រផ្លូវការ ឬតាមមធ្យោបាយទំនាក់ទំនង ផ្សេងទៀតរបស់ ធនាគារ ព្រីនស៍។

៧. បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវបានគ្រប់គ្រងដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ រាល់វិវាទ ដែលកើតឡើង ឬទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ នឹងត្រូវបានដោះស្រាយ ដោយអនុលោមតាម គោលនយោបាយដោះស្រាយបណ្តឹងអតិថិជនរបស់ធនាគារ និងតុលាការមានសមត្ថកិច្ចនៃព្រះរាជាណា ចក្រកម្ពុជា។